ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
ក្រុងក្រចេះ ខេត្តក្រចេះ

# របាយការណ៍ស្តីពីទិន្នន័យដើមគ្រានៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង

## ១.ប្រវត្តិ:

ផែនការអនុវត្តរយៈពេលបីឆ្នាំ(ផអ៣) គឺជាផែនការគាំទ្រការអនុវត្តកម្មវិធីជាតិ សម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល ។ ផែនការនេះផ្តោត សំខាន់ទៅលើការរៀបចំឡើងនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង រួមជាមួយនឹងការបង្កើត និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អោយក្លាយទៅជាស្ថាប័នសម្រាប់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍមូលដ្ឋាន ប្រកបដោយប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធិក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ដោយរួមបញ្ចូលទាំង ការផ្តល់សេវាសាធារណៈ ស្របតាមគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ នាពេលបច្ចុប្បន្ននេះ រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងសំខាន់ៗនៃរដ្ឋបាលថ្នាក់នេះ ត្រូវបានរៀបចំឡើងវិញ និងកំពុងត្រូវបានដាក់អោយដំណើរការជាបណ្តើរៗក្នុងស្ថានភាពមួយដែលមានតំរូវការយ៉ាងខ្លាំងផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាព ។ អាស្រ័យហេតុនេះ កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព គឺជាកត្តាសត្យានុម័តក្នុងការកំណត់ពីភាពជោគជ័យនៃការងារកំណែទម្រង់នៃរដ្ឋបាលថ្នាក់ ក្រុង ស្រុក ខណ្ឌ នេះ ។

ផ្អែកតាម ផអ៣ នៅចុងឆ្នាំ ២០១៣ បុគ្គលិក និងអ្នកដឹកនាំទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសរដ្ឋបាល ក្រុង ស្រុក ខណ្ឌ នឹងមានសមត្ថភាពប្រើប្រាស់អោយអស់លទ្ធភាពនុវសក្តានុពល របស់ខ្លួនដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវដែលបានផ្ទេរអោយប្រកបដោយប្រសិទ្ធភាព ។

ក្នុងស្ថានភាពចំពោះមុខនេះ ដែលសមត្ថភាពរដ្ឋបាល ក្រុង ស្រុក ខណ្ឌនៅមានកំរិត នៅឡើយ សម្រាប់ការអនុវត្តតួនាទី ភារកិច្ច ដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អនុវត្តច្បាប់នេះ ។ ហេតុនេះអន្តរាគមន៍ភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌអនុវត្ត ផអ៣ នឹងត្រូវរៀបចំឡើងយ៉ាងច្រើនជាបន្តបន្ទាប់ ។

ដើម្បីបំពេញតម្រូវការនៅថ្នាក់មូលដ្ឋានក្នុងការលើកកម្ពស់អភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលក្រុង ការប្រមូលទិន្នន័យដើមគ្រា ត្រូវបានធ្វើក្នុងគោលបំណងស្វែងរកនូវចំណុចខ្លាំង ចំណុចខ្សោយរបស់រដ្ឋបាលក្រុង និងផ្តល់អនុសាសន៍សម្រាប់ធ្វើការកែលម្អអោយការអនុវត្តតួនាទី ភារកិច្ចរដ្ឋបាលក្រុងកាន់តែមានភាពប្រសើរឡើង ។

ក្រុងក្រចេះ ជាក្រុងមួយក្នុងចំណោមក្រុងមួយ និងស្រុកទាំងប្រាំរបស់ខេត្តក្រចេះ មានព្រំប្រទល់ខាងកើតជាប់នឹងឃុំដានៃស្រុកចិត្របុរី ខាងលិចទល់នឹងទន្លេមេគង្គ ស្រុកព្រែកប្រសព្វ ខាងជើងទល់នឹងឃុំថ្មគ្រែ និងឃុំគោលាប់ ស្រុកចិត្របុរី និងខាងត្បូងទល់នឹងឃុំបុសលាវ ស្រុកចិត្របុរី ។ ក្រុងក្រចេះមាន ៥សង្កាត់ និងមាន

១៦ភូមិ មានផ្ទៃដីសរុប ៨៨,៦៨ គីឡូម៉ែតការ៉េ មានប្រជាជនសរុប ៣០,៩៨៩ នាក់ ស្រី ១៥,៨៩៣ នាក់ មានដង់ស៊ីតេប្រជាជន ៣៤៩នាក់គីឡូ/ម៉ែតការ៉េ ។ ប្រជាពលរដ្ឋប្រមាណ៩៦.៥២ជាកសិករស់នៅ ពឹងផ្ %អែកលើ វិស័យកសិកម្ម ក្រៅពីវិស័យនេះនៅមានវិស័យមួយចំនួនទៀតដែលចូលរួមចំណែកសំខាន់នៃ ការអភិវឌ្ឍដូចជា សិប្បកម្ម និងសេវាកម្មជាដើម ។ ដោយមានការរៀបចំរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុងក្រចេះមានក្រុមប្រឹក្សាចំនួន១៣រូប ស្រី០១រូបគណៈអភិបាលចំនួន៣រូបស្រី ០១រូប នាយករងរដ្ឋបាល០១រូប និងមានការិយាល័យចំណុះ ៣ គឺ

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានមន្ត្រីចំនួន០៥នាក់ ស្រី០២នាក់
- ការិយាល័យផែនការ និងគាំទ្រឃុំ មានមន្ត្រីចំនួន០៣នាក់ ស្ត្រី០២នាក់
- ការិយាល័យអភិវឌ្ឍក្រុងមានមន្ត្រីចំនួន០៣នាក់ ស្ត្រី០២នាក់។

**២.គោលបំណង:**

គោលបំណងនៃការចុះប្រមូលទិន្នន័យដើមគ្រាអំពីសមត្ថភាពរបស់រដ្ឋបាលក្រុងក្រចេះគឺដើម្បីធានាអោយមានទិន្នន័យមូលដ្ឋានពាក់ព័ន្ធសមត្ថភាពរបស់រដ្ឋបាលក្រុង ដែលជាមូលដ្ឋានសំរាប់ការកំណត់តម្រូវការ និងការវាស់វែងពីភាពរីកចំរើននៃសមត្ថភាពរបស់រដ្ឋបាលក្នុងអំឡុងពេលអនុវត្ត និងនៅពេលបញ្ចប់ផអ៣នៃកម្មវិធីជាតិ ។

**៣-វិធីសាស្ត្រ:**

| វិធីសាស្ត្រ៖ | ឧបករណ៍៖ |
|---|---|
| - ពិនិត្យឯកសារដែលមាន(បញ្ជីសំណួរ(<br>ការសង្កេតផ្ទាល់(ចុះមូលដ្ឋានគោលដៅនៅសាលាក្រុងក្រចេះ(<br>សម្ភាសន៍(បុគ្គល ក្រុម និងអ្នកផ្តល់ព័តិមានសំខាន់ៗ(<br>- ការពិភាក្សាជាក្រុម។ | - បញ្ជីសំណួររៀបចំដោយថ្នាក់ជាតិ<br>- បញ្ជីសំណួរសម្រាប់សម្ភាសន៍បុគ្គល<br>- បញ្ជីសំណួរសម្រាប់ការពិភាក្សាក្រុម<br>- ទម្រង់និងគំរូសម្រាប់សរសេររបាយការណ៍ ។ |

**៤-លទ្ធផលនៃការអង្កេតទូទៅ**

**ការអង្កេតទូទៅ**

ក្រុមប្រឹក្សាក្រុងក្រចេះ បានបង្កលក្ខណៈឱ្យក្រុមការងារ ចុះប្រមូលទិន្នន័យដើមគ្រា ទាក់ទងនឹងសមត្ថភាពរបស់មន្ត្រីរដ្ឋបាលក្រុង ។ ជាមួយនេះ ការកត់សម្គាល់មួយទៀត បានបង្ហាញពីការយកចិត្តទុកដាក់ របស់រដ្ឋបាលក្រុង និងមានការលះបង់ខ្ពស់ក្នុងការចំណាយពេលវេលា ដើម្បីចូលរួមផ្តល់ព័តិមានដល់ក្រុមការងារ ក្នុងន័យរួមចំណែកអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ចំណុចខ្លាំង**

- ក្រុមប្រឹក្សាទាំងអស់បានបំពេញបញ្ជីសំណួរ រួមទាំងក្រុមប្រឹក្សាសង្កាត់
- គណៈអភិបាលទាំងអស់បានបំពេញបញ្ជីសំណួរ
- បុគ្គលិកទាំងអស់បានបំពេញបញ្ជីសំណួរ

**ចំណុចខ្សោយ**

- ក្រុមប្រឹក្សាពុំទាន់យល់ពីការអនុវត្តការងាររបស់គក.ស.ក.
- ការអនុវត្តពីតួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋបាលសាលាក្រុងពុំទាន់បាលល្អ ។

**៥-អនុសាសន៍**

ដើម្បីរួមចំណែកដល់ការលើកម្ពស់ប្រសិទ្ធភាពការងារ និងការធ្វើអោយប្រសើរនូវការអនុវត្ត តួនាទី និងភារកិច្ចរបស់រដ្ឋបាលក្រុងក្រចេះ ក្រុមប្រឹក្សាក្រុងគួរយក ចិត្តទុកដាក់ទៅលើចំណុចមួយចំនួនដូចខាងក្រោមៈ

1. គួរពង្រឹងយន្តការគាំទ្រពីថ្នាក់ខេត្តដល់រដ្ឋបាលក្រុង
2. គួរពង្រឹងយន្តការគាំទ្រពីថ្នាក់រដ្ឋបាលក្រុងដល់រដ្ឋបាលសង្កាត់
3. ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ស្រុក ក្រុងគួរធ្វើការពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាអំពីការពាក់ព័ន្ធមួយចំនួន ដូចជាការអនុវត្តការងាររបស់ គ.ក.ស.ក លើការរៀបចំផែនការសកម្មភាពប្រចាំត្រីមាស និងប្រចាំខែ ព្រមទាំងការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់គ.ក.ស.ក ការជួយគាំទ្រគ.ក.ស.ក
4. គណៈអភិបាលក្រុង គួរពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់នាយករដ្ឋបាល និងការិយាល័យទាំងបីរបស់ក្រុង ។
5. គួររៀបចំអោយមានការិយាល័យរបស់ការិយាល័យទាំងបីរបស់ក្រុងដើម្បីងាយស្រួលបំពេញការងារ ។
6. គួរជ្រើសរើសបុគ្គលិកបន្ថែមដោយសារសព្វថ្ងៃខ្វះទាំងគណៈអភិបាល នាយករដ្ឋបាល និងមន្ត្រី ។

ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១២

អ្នកសរសេររបាយការណ៍

**ពត ភុំ**